**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២ ខែ មិនា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Mar-2012, 09:12
CMS/CFO: Kauv Keoratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អជសដ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបទៅនឹង "សំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្ដីពីផលវិបាកនានានៃការបដិសេធមិនឆ្លើយតបរបស់លោក ទៅនឹងសំណួរនៅក្នុងសវនាការ"**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> |
|---|---|
| **សហមេធាវីការពារក្ដីលោក ខៀវ សំផន** | **អង្គជំនុំជម្រះសាលាដំបូង** |
| លោក គង់ សំអុន | ចៅក្រម និល ណុន |
| លោក Arthur VERCKEN | ចៅក្រម Silvia CARTWRIGHT |
| លោក Jacques VERGÈS | ចៅក្រម យ៉ូរ ឧត្តរា |
| **ជំនួយការ៖** | ចៅក្រម Jean-Marc LAVERGNE |

| | |
|---|---|
| លោកស្រី សេង សុជាតា | ចៅក្រម យ៉ា សុខន |
| កញ្ញា Marie CAPOTORTO | |
| កញ្ញា Shéhérazade BOUARFA | **សហព្រះរាជអាជ្ញា៖** |
| កញ្ញា Clémence WITT | លោកស្រី ជា លាង |
| កញ្ញា Mathilde CHIFFERT | លោក Andrew CAYLEY |
| កញ្ញា អ៊ូច ស្រីផាត | **មេធាវីដើមបណ្តឹងរដ្ឋប្បវេណីវេណីទាំងអស់** |
| លោក Samy SALOMON | **ក្រុមមេធាវីការពារក្តីទាំងអស់** |

# សូមគោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. តាមរយៈបណ្តឹងមួយដែលមានចំណងជើងថា “*សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការបដិសេធមិនឆ្លើយតបរបស់លោកទៅនឹងសំណួរនៅក្នុងសវនាការ*” ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ហើយដែលបានជូនដំណឹងជាភាសាបារាំងកាលពីថ្ងៃទី ២៧ ខែ កុម្ភៈ (“បណ្តឹង”) សហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះ៖

*“២៦. (...) ជូនដំណឹងដល់ជនជាប់ចោទថា បើសិនជាគាត់បដិសេធមិនឆ្លើយនឹងសំណួរនៅពេលជំនុំជម្រះ៖*

*(ក) ចម្លើយផ្ទាល់មាត់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ ទំនងជានឹងមិនស្របទៅនឹងទម្ងន់នៃភស្តុតាងសំខាន់ៗទេ ហើយ*

*(ខ) អង្គជំនុំជម្រះអាចទាញយកការពិចារណាអវិជ្ជមានចេញពីការបដិសេធដូច្នេះ ក្នុងការវាយតម្លៃអំពីភស្តុតាងនៅលើបញ្ហានៃការពាក់ព័ន្ធ និងការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។*

*២៧. ជាចុងក្រោយ ដើម្បីជាប្រយោជន៍នៃការគ្រប់គ្រងសវនាការឲ្យមានរបៀបរៀបរយ និងត្រឹមត្រូវយុត្តិធម៌ដល់ភាគីទាំងអស់ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះបង្គាប់ ខៀវ សំផន ឲ្យនិយាយនៅពេលឥឡូវនេះ ១) ថាគាត់មានចេតនាឆ្លើយនឹងសំណួរផ្សេងៗដែរឬក៏អត់ និង ២) បើសិនជាគាត់មានចេតនាឆ្លើយនឹងសំណួរ ថាតើគាត់នឹងធ្វើនៅក្នុងវគ្គសវនាការនីមួយៗ ឬគ្រាន់តែនៅចុងបញ្ចប់នៃកិច្ច*

*ដំណើរការនីតិវិធី គឺនៅពេលដែលភស្តុតាងត្រូវបានបង្ហាញនៅគ្រប់វគ្គ និងដំណាក់កាលទាំងអស់នៃការជំនុំជម្រះ។*[1]"

## រំលឹកអំពីគោលការណ៍ជាសារវ័ន្ត

២. បើផ្អែកលើអំណះអំណាងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ ដែលតាមរយៈឥរិយាបថរបស់លោកនៅក្នុងពេលសវនាការ ទំនងជាបានលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់លោក[2]។ ជំហររបស់សហព្រះរាជអាជ្ញាបញ្ជាក់ឲ្យឃើញថា រាល់ចម្លើយនានារបស់ជនជាប់ចោទដែលបានផ្តល់ក្នុងអំឡុងពេលសវនាការ មានតម្លៃជាការលះបង់យ៉ាងជាក់ច្បាស់នូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់។ ទស្សនៈនេះជាទស្សនៈដែលមានការខុសឆ្គង ដោយហេតុថាវាមានភាពផ្ទុយគ្នាទាំងស្រុងទៅនឹងគោលការណ៍ ដែលមានក្នុងវិធានផ្ទៃក្នុង។

៣. គួររំលឹកផងដែរថា វិធាន ២១ នៃវិធានផ្ទៃក្នុងបានចែងថា៖

***"វិធាន ២១. គោលការណ៍ជាសារវ័ត្ត***

*១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖*

---

[1] *សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹង ដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការបដិសេធមិនឆ្លើយតបទៅនឹងសំណួរនៅក្នុង សវនាការ"* ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារតុលាការ E174។

[2] បណ្តឹង កថាខណ្ឌ ១៣។

*ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាឲ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និង អាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។*

*ខ-បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។*

*គ- អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធី នៃរឿងក្តី។*

*ឃ-ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និង មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិង**<u>នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប</u>**(...)"* (គូសបន្ទាត់ពីក្រោមដោយអ្នកតាក់តែង)

៤. ខ្លឹមសារនៃវិធាន ២១.១. នេះ ក៏ត្រូវបានរំលឹកឡើងវិញផងដែរនៅក្នុងវិធាន ៩០ នៃវិធានផ្ទៃក្នុងដែលចែងអំពីការសួរចម្លើយជនជាប់ចោទ។

៥. ជាមួយគ្នានេះសិទ្ធិរបស់ជនជាប់ចោទក្នុងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងដែលសិទ្ធិនេះជាជើងទម្រនៃសិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺជាគោលការណ៍ជាសារវ័ន្តមួយដែលបានទទួលស្គាល់យ៉ាងច្បាស់ដោយវិធានផ្ទៃក្នុងនៃ អ.វ.ត.ក.។ ដោយផ្អែកលើមូលដ្ឋាននេះហើយ ទើបបានជានៅរាល់ពេលដែលមានការតាំងសំណួរចំពោះលោក ខៀវ សំផន ឬជនជាប់ចោទដទៃទៀត ឬនៅរាល់ពេលដែលមានការបង្ហាញ

ឯកសារណាមួយចំពោះពួកគាត់ គេតែងតែចោទសួរទៅពួកគាត់ថា តើពួកគាត់មានបំណងធ្វើការឆ្លើយតប ឬមួយពួកគាត់ចង់នៅស្ងៀមមិនធ្វើការឆ្លើយតប។ ប្រសិនណាជាពួកគាត់មិនចង់ធ្វើការឆ្លើយតប ពេលនោះ សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ពួកគាត់ត្រូវបានគោរព។

៦. ជាមួយគ្នានេះ នៅក្នុងអង្គសវនាការដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ក្រោយពេលដែលលោក ខៀវ សំផន បានបង្ហាញនូវជំហររបស់លោករួចមក លោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រកាសថា[3]៖

*"ឥឡូវនេះ លោករក្សាសិទ្ធិក្នុងការមិនទាន់ឆ្លើយតបនោះទេ។ ប៉ុន្តែលោកស្នើសុំធ្វើការសង្កេត ឬក៏ថ្លែងការណ៍ទៅលើខ្លឹមសារនៃបណ្តាកថាខណ្ឌដែលក្រឡាបញ្ជីរបស់អង្គជំនុំជម្រះបានអាន កាលពីថ្ងៃច័ន្ទ ខែ ធ្នូ កាលពីសប្តាហ៍មុនកន្លងមកហើយនេះ។ អ៊ីចឹង ពិតមែនដែរឬទេ លោក ខៀវ សំផន?*

*បើដូច្នោះមែន **<u>អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំរបស់លោក។ សូមអញ្ជើញ!</u>** (គូសបន្ទាត់ពីក្រោមដោយអ្នកសរសេរចម្លើយតបនេះ)*

៧. កាលពីសវនាការថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ នៅក្នុងពេលដែលស្នើដល់ជនជាប់ចោទឲ្យធ្វើកំណត់សម្គាល់របស់ខ្លួន លោកចៅក្រម LAVERGNE បានរំលឹកជាច្រើនដងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបនេះ៖

*" ដូច្នេះ នេះជាមូលហេតុដែលឯកសារទាំងនេះនឹងត្រូវបានបង្ហាញ ហើយនៅពេលក្រោយឯកសារទាំងនេះនឹងត្រូវបានអានតាមរយៈអត្ថបទដកស្រង់ ហើយលោកមានលទ្ធភាពធ្វើកំណត់សម្គាល់នានាទៅលើឯកសារទាំងនោះ។ **<u>ប្រសិនណាជាលោកមិនចង់ឆ្លើយតបទៅនឹងឯកសារដែលនឹងបង្ហាញចំពោះលោកនោះទេ ក៏មិនជាបញ្ហាអ្វីដែរ</u>** ក៏ប៉ុន្តែ លោកត្រូវយល់ឲ្យច្បាស់ថា លោកត្រូវបានផ្តល់ឱកាសឲ្យធ្វើកំណត់*

---

[3] ប្រតិចារិកសវនាការ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១។ ឯកសារលេខ E1/21/1 ទំព័រ ៧៦ បន្ទាត់ទី ១៦ ដល់ ២២ (ភាសាបារាំង)។

*សម្គាល់នាថ្ងៃនេះ។”*[4]

*“ (...) ឯកសារទាំងនេះដែលអង្គជំនុំជម្រះចាត់ទុកថា អាចមានភាពសមហេតុសមផល នឹងត្រូវដាក់បង្ហាញជូនអង្គសវនាការ បង្ហាញជូនលោក ខៀវ សំផន **និង ហើយ... លោក ខៀវ សំផន នឹងមានលទ្ធភាពធ្វើការឆ្លើយតប ហើយគាត់នឹងមានលទ្ធភាពធ្វើកំណត់សម្គាល់នានា**។ នេះជាអ្វីដែលតុលាការចង់ធ្វើនៅពេលនេះ។”*[5]

៨. ក្នុងអំឡុងសវនាការដដែលនោះ លោកប្រធានអង្គជំនុំជម្រះ បានប្រកាសទទួលស្គាល់ការប្រកាន់ជំហររបស់ជនជាប់ចោទ ដូចដែលបានដកស្រង់ខាងក្រោម៖

*"លោក ហ្សង់ម៉ាក លោកអាចបន្តនីតិវិធីបាន ហើយ**តាមជំហររបស់ជនជាប់ចោទ និងមេធាវីបានបង្ហាញច្បាស់លាស់ហើយ** គាត់មិនចង់ធ្វើអត្ថាធិប្បាយ ឬក៏សង្កេតទៅលើឯកសារភស្តុតាងដែលអង្គជំនុំជម្រះដាក់ចំពោះមុខភាគី។ ដូច្នេះកុំឱ្យមានការពេលពន្យារពេលវេលាក្នុងកិច្ចដំណើរការសវនាការយូរ សូមឱ្យលោកចៅក្រមធ្វើការបង្ហាញការដាក់ឯកសារចំពោះមុខភាគីដោយបង្ហាញអំពីកម្រិតត្រឹមតែអត្តសញ្ញាណឯកសារ ដើម្បីពន្លឿនកិច្ចដំណើរការនេះ។ ហើយ**យើងសង្កេតឃើញច្បាស់លាស់ហើយថា គាត់បានលះបង់សិទ្ធិនៅក្នុងការឆ្លើយតបនឹងសំណួរនោះជារឿងមួយ។** ឥឡូវសូម្បីតែធ្វើការសង្កេត ឬក៏ធ្វើការអត្ថាធិប្បាយនូវអ្វីដែលជាការបង្ហាញរបស់អង្គជំនុំជម្រះចំពោះខ្លឹមសារនៃស្នាដៃនិពន្ធរបស់គាត់ ក៏គាត់មិន... លះបង់សិទ្ធិ បានន័យថាមិនធ្វើការសង្កេតដែរ។*[6]*”*

៩. ជាមួយគ្នានេះដែរ ប្រសិនណាជាលោកចៅក្រម ស្នើសុំសាជាថ្មីឱ្យជនជាប់ចោទធ្វើអត្ថាធិប្បាយទៅលើឯកសារ នៅក្នុងសវនាការថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ក៏ស្ថិតក្នុងក្របណ្ឌនៃការគោរពដល់សិទ្ធិនៅ

---

[4] ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/26.1 ទំព័រ ៥៨ បន្ទាត់ទី ២១-២៥ និងទំព័រ ៥៩ បន្ទាត់ទី ១-២។

[5] *យោងដូចខាងលើ* ទំព័រ ៦៣ បន្ទាត់ទី ២៣-២៥ និងទំព័រ ៥៩ បន្ទាត់ទី ១-២។

[6] *យោងដូចខាងលើ* ទំព័រ ៧៦ បន្ទាត់ទី ១៩-២៥ និងទំព័រ ៧៧ បន្ទាត់ទី ១-៦។

ស្ងៀមមិនឆ្លើយតបដែរ៖

*"(...) ខ្ញុំគ្រាន់តែចង់ឲ្យទាំងជនជាប់ចោទ នួន ជា ក៏ដូចជាជនជាប់ចោទដ៏ទៃទៀត **ប្រសិនបើពួកគាត់ចង់អាចបញ្ចេញប្រតិកម្ម** តបនឹងឯកសារទាំងអស់ដែលខ្ញុំនឹងយកមកបង្ហាញនេះ។"*[7]

*"សូមអរគុណ។ ខ្ញុំមិនដឹងថា តើជនជាប់ចោទ ខៀវ សំផន គាត់ចង់មានប្រតិកម្មអ្វីនោះទេ។ ខ្ញុំគ្រាន់តែចង់ជម្រាប់លោកថា **លោក ខៀវ សំផន លោកអាចមានលទ្ធភាពក្នុងការធ្វើប្រតិកម្មតបបាន ប្រសិនបើលោកចង់**។"*[8]

*"ខ្ញុំមិនដឹងថា តើលោក ខៀវ សំផន ឬក៏លោក អៀង សារី ពីព្រោះលោក អៀង សារី គាត់អាចស្តាប់ពីមន្ទីរឃុំឃាំងបាន **ថា តើអ្នកទាំងពីរនេះចង់ធ្វើការឆ្លើយតប**ទៅលើការអានឯកសារដែលខ្ញុំទើបនឹងធ្វើការដាក់បង្ហាញនេះ ឬប្រសិនបើពួកគាត់ចង់ផ្តល់សេចក្តីសង្កេតអីទៅលើឯកសារទាំងនេះ"។*

១០. ជាទីបញ្ចប់ នាសវនាការថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានធ្វើការរំលឹក យ៉ាងច្បាស់លាស់អំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតប៖

*"មុននឹងចាប់ផ្តើមនូវកិច្ចដំណើរការ អង្គជម្រះសូម**រំឭកទៅដល់ជនជាប់ចោទ ជាពិសេសគឺ លោក អៀង សារី ហើយនិងលោក ខៀវ សំផន ដែលអង្គជំនុំជម្រះបានដឹងច្បាស់អំពីការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប** មិនធ្វើអត្ថាធិប្បាយអ្វីផ្សេងៗ ចំពោះកិច្ចដំណើរការពិភាក្សាដេញដោល នៅក្នុងដំណាក់កាលនេះ ហើយដោយឡែកគឺលោក អៀង សារី គឺបានប្រើសិទ្ធិជារហូត។ ប៉ុន្តែអង្គជម្រះសូមរំឭកថា នាពេលនេះ អង្គជម្រះរៀបចំនូវកិច្ចដំណើរការនីតិវិធីដាក់ឯកសារភស្តុតាងចំពោះមុខភាគី។ ដូច្នេះឱកាសនេះ គឺជនជាប់ចោទមានឱកាសនៅក្នុងការធ្វើការកត់សម្គាល់ ឬក៏ធ្វើអត្ថាធិប្បាយផ្សេងៗទៅលើឯកសារដែលអង្គជំនុំ*

---

[7] ប្រតិចារឹក ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E1/40.1 ទំព័រ ១៨ បន្ទាត់ទី ៩-១២ (ភាសាបារាំង)។

[8] *យោងដូចខាងលើ* ទំព័រ ២៣ បន្ទាត់ទី ២-៤(ភាសាបារាំង)។

*ជម្រះបានដាក់ចំពោះមុខភាគី ឬក៏ភាគីបានដាក់ចំពោះមុខអង្គជំនុំជម្រះ។ នេះជាសិទ្ធិប្រសិនបើជនជាប់ចោទប្រើសិទ្ធិនេះ។”*[9]

១១. អង្គជំនុំជម្រះបានទទួលស្គាល់យ៉ាងជាក់ច្បាស់នូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ។ នៅក្នុងបរិបទនេះ សំណើសុំរបស់សហព្រះរាជអាជ្ញា ពុំមែនមិនត្រឹមតែមានគោលដៅស្នើសុំដល់អង្គជំនុំជម្រះឲ្យប្រកាសនូវអ្វីដែលផ្ទុយពីការប្រកាសដែលអង្គជំនុំជម្រះធ្លាប់ធ្វើពីពេលមុនៗប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះ សំណើសុំនោះថែមទាំងបានយោងទៅលើការបកស្រាយដោយខុសឆ្គងនូវយុត្តិសាស្ត្រទៀតផង។

## ការបកស្រាយដោយខុសឆ្គងនូវយុត្តិសាស្ត្រពីសំណាក់សហព្រះរាជអាជ្ញា

១២. នៅក្នុងករណីដែលពុំមានវិធានចែងច្បាស់លាស់អំពី ការផ្តល់ចម្លើយពីសំណាក់ជនជាប់ចោទ ក្រៅអំពីការផ្តល់ចម្លើយបឋមនោះ សហព្រះរាជអាជ្ញាបានយោងទៅលើយុត្តិសាស្ត្រអន្តរជាតិ។ ក៏ប៉ុន្តែ ស្ថានភាពដែលសហព្រះរាជអាជ្ញាបានធ្វើការប្រៀបប្រដូចទៅនឹងករណីនៃយុត្តិសាស្ត្រនោះ មានលក្ខណៈមិនអាចប្រៀបធៀបគ្នាបានឡើយ។

១៣. តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គូស្លាវី មានបទបញ្ញត្តិរបស់ខ្លួនដែលបែងចែកចម្លើយរបស់ជនជាប់ចោទ អាស្រ័យទៅលើថា តើជនជាប់ចោទនោះផ្តល់ចម្លើយក្នុងនាមជាសាក្សី ឬ ក៏ពុំមែនជាសាក្សី។ យុត្តិសាស្ត្ររបស់តុលាការទាំងពីរនេះ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង មិនអាចយកទៅអនុវត្តលើករណីលោក ខៀវ សំផន បានទេ។

១៤. ជាក់ស្តែង ដើម្បីយល់ឲ្យបានច្បាស់អំពីខ្លឹមសារនៃសេចក្តីសម្រេចចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១១ នៅ

[9] ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E1/41.1 ទំព័រ ១ បន្ទាត់ទី ៧-១៤ (ភាសាបារាំង)។

ក្នុងរឿងក្ដី *សហព្រះរាជអាជ្ញា ប្ដឹងទល់នឹង KATANGA* ដែលសហព្រះរាជអាជ្ញាបានលើកឡើង [10] គេត្រូវអានម្ដងទៀតនូវមាត្រា ៦៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាមុន សិន[11]។

*មាត្រា ៦៧ ៖ អំពីសិទ្ធិរបស់ជនជាប់ចោទ*

*១. ក្នុងការកំណត់បទចោទប្រកាន់ណាមួយ ដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ជនជាប់ចោទ ត្រូវមានសិទ្ធិទទួលបាននូវសវនាការជាសាធារណៈ សវនាការដ៏យុត្តិធម៌មួយដែលធ្វើឡើងដោយឥតលំអៀង និង មានសិទ្ធិទទួលនូវការធានាជាអប្បបរិមា ដោយសមភាពបំផុត ដូចតទៅនេះ ៖*

*(...)*

*ឆ) មិនត្រូវបានបង្ខំឱ្យផ្ដល់សក្ខីកម្ម ឬ សារភាពទទួលពិរុទ្ធភាព និង នៅស្ងៀមស្ងាត់នោះទេ ដោយការនៅស្ងៀមស្ងាត់នោះមិនត្រូវបានយកមកធ្វើជាការពិចារណាក្នុងការកំណត់ថាមាន ពិរុទ្ធ ឬ និរទោសឡើយ។*

*ជ) <u>ត្រូវធ្វើការថ្លែងដោយផ្ទាល់មាត់ ឬ ជាលាយល័ក្ខអក្សរដោយគ្មានសម្បថ នៅក្នុងការការពារខ្លួន</u> និង*

*ឈ) មិនត្រូវបានបង្ខំឱ្យត្រលប់បន្ទុកនៃភស្តុតាងឡើយ។" (គូសបន្ទាត់ពីក្រោមដោយអ្នកតាក់តែង)*

---

[10] *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង* *Germain Katanga និង Mathieu Ngudjolo Chui* សំណុំរឿងលេខ ICC-01/04-01/07 *សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីឱ្យ Mathieu Ngudjolo សុំឱ្យបានទទួលការធានាទាក់ទងនឹងការធ្វើពិរុទ្ធកម្មប្រឆាំងនឹងខ្លួនឯងសម្រាប់ជនជាប់ចោទ*ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១១។

[11] មាត្រា ៦៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។

១៥. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា បានយោងទៅយ៉ាងជាក់ច្បាស់ទៅលើករណីដែលជនជាប់ចោទស្ម័គ្រចិត្តផ្តល់សក្ខីកម្មដោយមានសម្បថ។ ដោយឡែក ការផ្តល់សក្ខីកម្មដោយមានសម្បថនេះ ពុំមានចែងនៅក្នុងបទបញ្ញត្តិរបស់ អ.វ.ត.ក. ឡើយ ហើយលោក ខៀវ សំផន ផ្ទាល់ ក៏ពុំបានស្នើសុំដូច្នោះដែរ។

១៦. មានតែមាត្រា ៦៧.១.ជ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិមួយទេ ដែលអាចធ្វើជាមូលដ្ឋានសម្រាប់ការវិភាគទៅលើគោលជំហររបស់លោក ខៀវ សំផន ដែលលោកបានយល់ព្រមផ្តល់សក្ខីកម្មផ្ទាល់មាត់ដើម្បីការពាររូបលោកនៅចំពោះមុខតុលាការ ដោយពុំមានការធ្វើសម្បថនោះ។ ការបកស្រាយយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពីសំណាក់សហព្រះរាជអាជ្ញា មិនសមស្របទៅនឹងករណីជាក់ស្តែងរបស់លោក ខៀវ សំផន ឡើយ។

១៧. ជាមួយគ្នានេះដែរ វាជាកំហុសឆ្គងក្នុងការដែលសហព្រះរាជអាជ្ញាយោងទៅលើសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី គឺករណីរឿងក្តី *សហព្រះរាជអាជ្ញាប្តឹងទល់នឹង GOTOVINA et consorts* ដោយព្យាយាមសម្របករណីរឿងក្តីនេះទៅនឹងស្ថានភាពរបស់លោក ខៀវ សំផន។[12] ត្រង់ចំណុចនេះ គេគួរតែក្រឡេកមើលអត្ថបទច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី។ មាត្រា ៨៤ ស្ទួន នៃវិធាននីតិវិធី និង វិធានភស្តុតាង នៃ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គូស្លាវី បានចែងនូវបទបញ្ញតិពិសេសទាក់ទងនឹងការណ៍ដែលជនជាប់ចោទធ្វើសេចក្តី ថ្លែងការណ៍ក្រោយពីការធ្វើសេចក្តីថ្លែងការណ៍បឋមរបស់ភាគី ដូចខាងក្រោម៖

“ ***មាត្រា ៨៤ ស្ទួន សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ***

*ក. ក្រោយការធ្វើសេចក្តីថ្លែងការណ៍បឋមរបស់ភាគី ឬ ប្រសិនណាជាមេធាវីការពារ ដោយអនុវត្តតាមមាត្រា ៨៤ មានបំណងធ្វើសេចក្តីថ្លែងការណ៍បឋមរបស់ខ្លួនក្រោយការធ្វើសេចក្តីថ្លែងការណ៍បឋម*

[12] សំណើ កថាខណ្ឌ ២៣

*របស់សហព្រះរាជអាជ្ញា ជនជាប់ចោទអាចផ្តល់សក្ខីកម្មបាន ប្រសិនណាជាជនជាប់ចោទមានបំណងចង់ផ្តល់ ដោយមានការយល់ព្រម និងក្រោមការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង។ ជនជាប់ចោទមិនតម្រូវឲ្យធ្វើសេចក្តីថ្លែងការណ៍ជាឱឡារិកនោះទេ ហើយក៏ត្រូវបានចោទសួរពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការផ្តល់សក្ខីកម្មនោះដែរ។*

*ខ. អង្គជំនុំជម្រះសាលាដំបូងធ្វើការវិនិច្ឆ័យទៅលើភាពដែលអាចយកជាការបាននៃសក្ខីកម្មដែលផ្តល់ដោយជនជាប់ចោទនោះ។"*

១៨. ដោយឡែក សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទនោះ ពុំមានជាប់ទាក់ទងជាមួយអង្គហេតុដែលថា ជនជាប់ចោទបានជ្រើសរើសការធ្វើសេចក្តីថ្លែងការណ៍ក្នុងឋានៈជាសាក្សី ដោយអនុវត្តតាមមាត្រា ៨៥ នៃវិធាននីតិវិធី និង ភស្តុតាង[13] (ដែលមានចែងផងដែរនៅក្នុងវិធាននីតិវិធី និង ភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ដែលបានចែងនៅក្នុងកថាខណ្ឌ (គ) របស់ខ្លួនថា៖

*"ជនជាប់ចោទអាចធ្វើការបង្ហាញខ្លួនក្នុងឋានៈជាសាក្សី ដើម្បីធ្វើការការពារខ្លួននៅចំពោះមុខតុលាការបាន ប្រសិនណាជាគេចង់ធ្វើដូច្នោះ។"*

១៩. ជាមួយគ្នានេះដែរ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនានាក៏ដូចជានៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មានការបែងចែកភាពខុសគ្នាយ៉ាងជាក់ច្បាស់រវាងសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយជនជាប់ចោទនៅក្នុងពេលសវនាការ និងការផ្តល់សក្ខីកម្មនានារបស់ជនជាប់ចោទក្នុងឋានៈជាសាក្សីដើម្បីធ្វើការការពារខ្លួន។ ការបែងចែកនេះត្រូវបានចែងដោយអត្ថបទច្បាប់នានា ហើយវាស្របគ្នាទៅនឹងទស្សនាទាននៃពិរុទ្ធភាពសុទ្ធសាធ ដែលតាមរយៈនោះ ជនជាប់ចោទអាចជ្រើសរើសការបង្ហាញខ្លួននៅចំពោះមុខចៅក្រមក្នុងឋានៈជាសាក្សីមួយរូបដូចអ្នកដទៃទៀតបាន។

[13] មាត្រា ៨៥ នៃវិធាននៃនីតិវិធី និងភ័ស្តុតាង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គូស្លាវី។

## ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក. មិនអាចត្រូវបានប្រៀបប្រដូចទៅនឹងសាក្សីមួយរូបដែលអាចធ្វើសម្បថបានឡើយ

២០. វិធានដែលចែងអំពីឋានៈជាសាក្សីនៅចំពោះមុខ អ.វ.ត.ក. ត្រូវបានដកស្រង់ចេញពីគោលគំនិតនៃប្រព័ន្ធច្បាប់បែបបារាំង និងប្រព័ន្ធច្បាប់របស់កម្ពុជា ដែលប្រព័ន្ធច្បាប់នេះបានចាត់ទុកសាក្សីមួយចំនួន ថាមានលក្ខណៈពិសេស ដោយហេតុថាពួកគេមានទំនាក់ទំនងជិតស្និទ្ធទៅនឹងជនជាប់ចោទ។ ផ្អែកលើលក្ខខណ្ឌទាំងនេះហើយ ទើបវិធាន ២៤ បានចែងថា៖

*"(...)*

២. សាក្សីដូចរៀបរាប់ខាងក្រោមត្រូវឆ្លើយដោយមិនចាំបាច់ធ្វើសម្បថ ៖

ក-ឪពុក ម្ដាយ និង បុព្វញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី។

ខ-កូនស្រី កូនប្រុស និង បច្ឆាញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ។

គ-បងប្អូនប្រុសស្រីរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ។

ឃ-បងប្អូនថ្លៃប្រុសស្រីរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ។

ង-សហព័ទ្ធរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ទោះបីពួកជាបានលែងលះគ្នាហើយ ក៏ដោយ និង

ច-ក្មេងដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ។

២១. ប្រសិនណាជាសាច់ញាតិរបស់ជនជាប់ចោទមិនត្រូវធ្វើសម្បថ ដូច្នេះ ជនជាប់ចោទក៏មិនត្រូវធ្វើសម្បថដែរ។ ដូច្នេះ វាជារឿងមួយខុសឆ្គង ខណៈដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យធ្វើការប្រៀបប្រដូចសេចក្តី

ថ្លែងការណ៍របស់ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក. ទៅនឹង *"សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទដែលបានជ្រើសរើសយកការផ្តល់សក្ខីកម្ម និងបានធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ឬនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ"*[14] នោះ។ ក្របខណ្ឌនៃជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក. ពុំអាចប្រៀបប្រដូចទៅនឹងក្របខណ្ឌនៃ សាក្សី ឬសាក្សីដែលធ្វើសម្បថ បានឡើយ។

២២. ជាទីបញ្ចប់ ពាក់ព័ន្ធនឹងតម្លៃដែលអង្គជំនុំជម្រះបានផ្តល់សេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន មេធាវីការពារយល់ឃើញថា វាពុំមែនជាសិទ្ធិរបស់សហព្រះរាជអាជ្ញាឡើយ ក្នុងការប្រាប់ទៅអង្គជំនុំជម្រះអំពីទម្ងន់ដែលអង្គជំនុំជម្រះត្រូវផ្តល់ដល់ចំពោះសេចក្តីថ្លែងការណ៍ទាំងនោះ។ វិធានភស្តុតាងមានលក្ខណៈច្បាស់លាស់ *"បន្ទុកនៃភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពនៃជនជាប់ចោទ ធ្លាក់ទៅលើសហព្រះរាជអាជ្ញា"* ហើយអង្គជំនុំជម្រះត្រូវសម្រេចអំពីពិរុទ្ធភាពរបស់ជនជាប់ចោទដោយផ្អែកទៅលើរាល់ភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។[15]

២៣. ក្នុងការស្នើសុំដល់អង្គជំនុំជម្រះ នាដំណាក់កាលនៃកិច្ចពិភាក្សាដេញដោលនេះ ឱ្យធ្វើសេចក្តីសន្និដ្ឋានអវិជ្ជមាន ចំពោះភាពនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ វាគឺជាការរំលោភទាំងស្រុងទៅលើគោលគំនិត និង អត្ថបទនៃវិធានផ្ទៃក្នុង ហើយទង្វើនេះក៏មានគោលដៅផងដែរក្នុងការព្យាយាមត្រលប់បន្ទុកនៃភស្តុតាង។

---

[14] សំណើ កថាខណ្ឌ២៤។

[15] វិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

# ហេតុដូច្នេះ

២៤. ដោយអនុវត្តវិធាន ២១ នៃវិធានផ្ទៃក្នុង មេធាវីការពារសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **រំលឹកឡើងវិញ** ថាសិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺជាគោលការណ៍ជាសារវ័ន្ត ដែលធានាដល់ជនជាប់ចោទ នៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។

- **បដិសេធ** នូវរាល់វិធានការទាំងឡាយដែលបានស្នើសុំដោយព្រះរាជអាជ្ញា នៅក្នុងសំណើសុំរបស់ខ្លួនលេខ E174។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |